# ការគ្រប់គ្រងវិបត្តិសាកល — ទេសចរណ៍នៅប្រទេសកម្ពុជា និងក្នុងតំបន់

*អត្ថបទនេះ សង្ខេបពីបទបង្ហាញរបស់ លោក ហូ វណ្ណី[1] នៅក្នុងសន្និសីទស្តីពីចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៩ ។*

កម្ពុជា ជាប្រទេសគោលដៅទស្សនកិច្ចបេតិកភ័ណ្ឌវប្បធម៌ដ៏សំខាន់មួយ ។ នៅមុនពេលមានវិបត្តិ កម្ពុជាមានការរីកលូតលាស់ខាងទេសចរណ៍គួរឱ្យភ្ញាក់ផ្អើល ដោយសារសម្បត្តិវប្បធម៌ជាកេរ្តិ៍តំណែលនៃប្រវត្តិសាស្ត្រដ៏រុងរឿងរបស់ប្រទេសនេះ ក៏ដូចជា សម្បត្តិធម្មជាតិដ៏សំបូរ ព្រមទាំងទីតាំងជាយុទ្ធសាស្ត្រនៅក្នុងតំបន់មួយដែលកំពុងមានសន្ទុះ ។ ការរីកលូតលាស់នេះ ផ្អែកលើស្ថិរភាពដែលកម្ពុជាទទួលបានបន្ទាប់ពីមានសង្គ្រាមរ៉ាំរ៉ៃអស់ជាច្រើនទសវត្សរ៍ គួបផ្សំនឹងគោលនយោបាយរបស់រដ្ឋាភិបាល ដូចជា គោលនយោបាយបើកចំហជើងមេឃជាដើម ។ ភ្ញៀវទេសចរមកដល់កម្ពុជា បានកើនឡើងពី ២១៩.០០០នាក់ នៅឆ្នាំ១៩៩៧ រហូតដល់ជាង ២,១លាននាក់ នៅឆ្នាំ២០០៨ ដោយមានរយៈពេលស្នាក់នៅជាមធ្យម ៦,៥ថ្ងៃ និងផ្តល់ប្រាក់ចំណូលប្រហែល ១៥៩៥លានដុល្លារ ។

## ផលប៉ះពាល់នៃវិបត្តិនៅលើទេសចរណ៍ក្នុងស្រុក និងលើពិភពលោក

ការធ្លាក់ចុះសេដ្ឋកិច្ចជាសាកល ធ្វើឱ្យសកម្មភាពទេសចរណ៍នៅកម្ពុជា និងតំបន់ ឯទៀតក្នុងពិភពលោក ថយចុះ ។ វិស័យទេសចរណ៍ ងាយរងគ្រោះបំផុតនៅចំពោះមុខភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ច ដោយសារហេតុផល ដ៏សាមញ្ញមួយ គឺ នៅពេលសេដ្ឋកិច្ចតានតឹងយ៉ាប់យ៉ឺន មនុស្សទូទៅតែងរក្សាទុកប្រាក់កាសរបស់ពួកគេ សំរាប់ដោះស្រាយតំរូវការចាំបាច់ និងលាក់ទុកខ្លះទៀត "នៅក្រោមកន្ទេល" ។ ទង្វើបែបនេះ មិនបានបញ្ឈប់ ការធ្វើដំណើរទាំងស្រុងទេ ពីព្រោះមនុស្សនៅតែត្រូវធ្វើដំណើរទៅធ្វើជំនួញ និងចូលរួមក្នុងព្រឹត្តិការណ៍សង្គមសំខាន់ៗ មួយចំនួន ។ ទោះយ៉ាងនេះក្តី ចាប់តាំងពីឆមាសទី២ ឆ្នាំ២០០៨ មក វិបត្តិបានធ្វើឱ្យកំណើនទេសចរណ៍ពិភពលោក ធ្លាក់ចុះរហូតដល់កំរិតសូន្យតែម្តង ។ កត្តាផ្សេងៗទៀតដែលរួមចំណែកបង្កការធ្លាក់ចុះ រួមមាន ការឡើងថ្លៃខ្ពស់នៃប្រេងសាំង និងទំនិញប្រើប្រាស់ ការឡើងចុះយ៉ាងរហ័សនៃអត្រាប្តូរប្រាក់ និងការថយចុះទំនុកចិត្តរបស់អតិថិជន និងអាជីវករ ។ យោងតាមទិន្នន័យរបស់ អង្គការទេសចរណ៍ពិភពលោក នៃសហប្រជាជាតិ (UNWTO) ចំនួនភ្ញៀវទេសចរអន្តរជាតិសរុប នៅឆ្នាំ២០០៨ មាន ៩២៤លាននាក់ ឬកើនបានតែ ២% ប៉ុណ្ណោះ ធៀបនឹងឆ្នាំមុន ។ កំណើនទេសចរណ៍នៅកម្ពុជា ក៏បានរួមចុះធ្ងន់ធ្ងរបែបនេះដែរ ។ ធៀបនឹងឆ្នាំ២០០៧ ចំនួនភ្ញៀវទេសចរនៅឆ្នាំ២០០៨ កើនបាន ៥,៥% គឺទាបជាខ្លាំង ធៀបនឹងកំណើនលេខពីរខ្ទង់ដែលកម្ពុជាធ្លាប់ទទួលបានពីមុន ។ អត្រាស្នាក់នៅសណ្ឋាគារថ្នាក់ខ្ពស់នៅខេត្តសៀមរាប និងតំបន់ជុំវិញ បានធ្លាក់ចុះប្រហែល ២០-៤០% នៅចុងឆ្នាំ២០០៨ ។

## ចក្ខុវិស័យ កាលានុវត្តភាព និងបញ្ហាប្រឈម

ចក្ខុវិស័យសំរាប់វិស័យទេសចរណ៍ ឆ្នាំ២០០៩ មានលក្ខណៈតឹងខ្លាំងណាស់ ប៉ុន្តែមិនដល់ថ្នាក់ដោះស្រាយមិនបាននោះទេ ។ អង្គការ UNWTO បានស្មានទុកថា ទេសចរណ៍ពិភពលោកនឹងបន្តនៅស្ពឹកទ្រឹង ដោយសារលក្ខខណ្ឌដែលបង្កការធ្លាក់ចុះសេដ្ឋកិច្ចពិភពលោកនៅឆ្នាំ២០០៨ នឹងប្រែប្រួលកាន់តែអាក្រក់ឡើង ឬនៅតែគ្រប់គ្រងមិនទាន់បាន ។ គេគិតថា នៅឆ្នាំ២០០៩នេះ ចំនួនអ្នកដំណើរជាជនជាតិអាមេរិក នឹងធ្លាក់ចុះយ៉ាងច្រើន ហើយប្រជាជននៅចក្រភពអង់គ្លេស ប្រហែលនឹងជ្រើសយកដំណើរកំសាន្តក្នុងស្រុក ជាជាងដំណើរកំសាន្តជាលក្ខណៈអន្តរជាតិ ។ នៅឆ្នាំ២០០៨ ប្រជាជនប្រទេសអាល្លឺម៉ង់ប្រហែលជា ៣០% ចូលចិត្តធ្វើដំណើរកំសាន្តនៅក្នុងប្រទេសរបស់ពួកគេ ដោយសារភាពតានតឹងខាងថវិកា ហើយត្រឹមខែកុម្ភៈ ២០០៩ នៅមានប្រជាជន ៤០% ទៀតដែលមិនទាន់សំរេចចិត្តថា នឹងធ្វើដំណើរទៅជិតៗផ្ទះ ឬយ៉ាងណា ។ ម្យ៉ាងទៀត ដោយសារក្រុមហ៊ុនជាច្រើនក្នុងពិភពលោក កំពុងប្រឈមមុខនឹងស្ថានភាពតានតឹង ដូចនេះ ចំណាយរបស់ក្រុមហ៊ុនលើការធ្វើដំណើរ ក៏រំពឹងថានឹងថយចុះដែរ ដោយមានការប៉ាន់ស្មានមួយថា ការធ្វើដំណើរក្នុងការងារក្រុមហ៊ុន នឹងថយចុះដល់ទៅ ៨០% ។ យោងតាមសមាគមអ្នកដឹកនាំគោចររបស់ក្រុមហ៊ុន (Association of Corporate Travel Executives) ៧១% នៃក្រុមហ៊ុនដែលជាសមាជិករបស់ខ្លួន មានគំរោងថវិកាសំរាប់ការធ្វើដំណើរក្នុងឆ្នាំ២០០៩នេះ តិចជាងកាលពីឆ្នាំ២០០៧ ហើយអ្នកដែលធ្វើដំណើរក៏ត្រូវកាត់បន្ថយ ចំណាយផ្សេងៗដែរ ។ ដោយសារហេតុការណ៍ទាំងអស់នេះ គ្មានអ្វីគួរឱ្យភ្ញាក់ផ្អើលទេដែលនៅឆ្នាំ២០០៩ ក្រុមហ៊ុនបំរើសេវាធ្វើដំណើរ នឹងត្រូវប្រឈមនឹងស្ថានការណ៍កាន់តែលំបាកជាងឆ្នាំមុនទៀត ហើយមួយចំនួន អាចនឹងដួលរលំ ជាពិសេសក្រុមហ៊ុនដែលអនុវត្តអត្រាយកចំណេញកំរិតទាប ។ ម្យ៉ាងទៀត សុវត្ថិភាពការងាររបស់អ្នកបំរើការក្នុងផ្នែកនេះ ក៏ជួបគ្រោះថ្នាក់ដែរ ។ ដោយឡែក ក្រុមហ៊ុនបំរើសេវាធ្វើដំណើរធំៗមួយចំនួន បាននិងកំពុងកាត់បន្ថយបុគ្គលិករួចជាស្រេច ហើយយោងតាមស្ថានការណ៍កាន់តែលំបាកឡើង អាចមានការបញ្ឈប់បុគ្គលិកថែមទៀត ក្នុងពេលដ៏ខ្លីខាងមុខនេះ ។

សំរាប់វិស័យទេសចរណ៍នៅកម្ពុជា មានការវាយតម្លៃទូទៅថា នឹងត្រូវធ្លាក់កំណើនថែមទៀត ប៉ុន្តែពុំមានការមូលមតិគ្នាអំពីទំហំនៃការធ្លាក់ចុះនេះទេ ។ ក្រសួងទេសចរណ៍បានព្យាករណ៍ថា វិស័យទេសចរណ៍ នឹងបន្តកើនឡើងនៅឆ្នាំនេះ ហើយនៅឆ្នាំ២០១០ ភ្ញៀវទេសចរមកកម្ពុជានឹងកើនដល់ ៣លាននាក់ ។ ការព្យាករណ៍សុទិដ្ឋិនិយមនេះ វាផ្ទុយគ្នានឹងការទស្សទាយគួរឱ្យបារម្ភមួយថា នៅឆ្នាំ២០០៩ វិស័យទេសចរណ៍ នឹងធ្លាក់ចុះអស់ដល់ទៅ ៣% ។ ម្ចាស់សណ្ឋាគារ និងទីភ្នាក់ងារទេសចរណ៍មួយចំនួន បានរាយការណ៍មកហើយ ពីការថយចុះការកក់សេវា និងការសាកសួរព័ត៌មានផ្សេងៗពីសំណាក់ភ្ញៀវទេសចរ សំរាប់ឆ្នាំ២០០៩ ។ ប៉ុន្តែ ទីប្រឹក្សាទេសចរណ៍ឯករាជ្យមួយចំនួន មិនបានគិតថា ការលំបាកទាំងនេះវាធ្ងន់ធ្ងរខ្លាំងនោះទេ បើទោះជាពួកគេ បានដាស់តឿនថា ភ្ញៀវទេសចរដែលមកកំសាន្ត អាចកាត់បន្ថយការចំណាយខ្លះក៏ដោយ ។ ភាពទ្រឹងនៃកំណើន មានផលប៉ះពាល់មិនស្មើគ្នាគ្រប់កន្លែងទេ ។ ក្រុមហ៊ុនដែលបំរើទីផ្សារទេសចរណ៍បែបប្រណីត

១ លោក ហូ វណ្ណី ជាសហប្រធានក្រុមការងារវិស័យឯកជន ស្តីពីវិស័យទេសចរណ៍ និងជានាយកគ្រប់គ្រងទីភ្នាក់ងារទេសចរណ៍ World Express Tours and Travel Co.Ltd ។

ទំនងត្រូវជួបការលំបាក ច្រើនជាងក្រុមហ៊ុនដែលបំរើសេវាបែបសាមញ្ញដល់អ្នកដំណើរ ។ ដោយសារភាពតានតឹងនៃថវិកា ដូច្នេះតំរូវការផលិតផល និងសេវាមានតំលៃទាប នឹងត្រូវកើនឡើង ហើយគេអាចឃើញមានការផ្លាស់ប្តូរខ្លះៗនៅក្នុង សមាសភាពនៃទីផ្សារនៅឆ្នាំនេះ ។ ទេសចរបរទេសជាច្រើនក្នុងចំណោមភ្ញៀវ ២លាននាក់ ដែលចូលមកកម្ពុជា ក្នុងឆ្នាំ២០០៨ បានធ្វើដំណើរមកពីសហរដ្ឋអាមេរិក ចក្រភពអង់គ្លេស និង កូរ៉េខាងត្បូង ពោលគឺប្រទេសទាំង៣ ដែលប៉ះពាល់ខ្លាំងជាងគេដោយសារវិបត្តិសេដ្ឋកិច្ចសព្វថ្ងៃ ។

កម្ពុជា នៅមានឱកាសល្អមួយចំនួន ដែលអាចជួយលើកស្ទួយវិស័យទេសចរណ៍ឡើងវិញ ។ ទីមួយ ការឡើងថ្លៃប្រាក់ដុល្លារ និងប្រាក់អឺរ៉ូ អាចជំរុញឱ្យប្រជាជនអាមេរិក អឺរ៉ុប និងជប៉ុន បន្តធ្វើដំណើរទៅក្រៅប្រទេស ។ម្យ៉ាងវិញទៀត ដោយសារសេដ្ឋកិច្ចរបស់ចិន និងឥណ្ឌា នៅតែមានកំណើននោះ ដូច្នេះ ការធ្វើដំណើរចេញពីប្រទេសទាំងពីរ នឹងនៅតែកើនឡើងទោះបីយឺតៗជាងមុនក្តី ។ ការធ្វើដំណើរក្នុងស្រុក និងការធ្វើដំណើរខ្លីៗទៅក្រៅប្រទេស ទំនងជានឹងកើនឡើងច្រើនគួរសម ពីព្រោះប្រជាជនចូលចិត្តធ្វើដំណើរ ទៅកន្លែងនៅជិតៗស្រុកទេសរបស់ពួកគេ ។

ការវិភាគលំអិតបង្ហាញថា ការធ្លាក់ចុះនៃវិស័យទេសចរណ៍ មិនមែនសុទ្ធតែដោយសារការប៉ះទង្គិចពីខាងក្រៅនោះទេ ប៉ុន្តែក៏ដោយសារចំនុចខ្សោយផ្ទៃក្នុងផងដែរ ។ កម្ពុជានៅតែជាជំរើសគោលដៅទេសចរណ៍នៅក្រោយគេឆ្ងាយណាស់ក្នុងពិភពលោក ទោះបីជាមានទីតាំងល្អ មានកេរ្តិ៍ដំណែលវប្បធម៌ដ៏សំបូរ និងចំរុះបែបពីប្រវត្តិសាស្ត្រដ៏យូរលង់ និងមានការរីកចំរើនខាងទេសចរណ៍ល្អវិសេសក្នុងពេលកន្លងទៅនេះ ក៏ដោយ ។ លទ្ធផលនៅទាប គឺបង្កឡើងដោយហេដ្ឋារចនាសម្ព័ន្ធអន់ខ្សោយ កន្លែងស្នាក់នៅមិនគ្រប់គ្រាន់ កង្វះបុគ្គលិកមានគុណភាព និង សមត្ថភាពតិចក្នុងការដឹកជញ្ជូនតាមផ្លូវអាកាស ក៏ដូចជាបណ្តាញដឹកជញ្ជូន នៅខ្វះខាត ។

## គោលនយោបាយគួរអនុវត្ត

ឆ្នាំ២០០៩ រំពឹងថានឹងលំបាកតឹងតែងសំរាប់វិស័យទេសចរណ៍នៅកម្ពុជា ។ ប៉ុន្តែមានហេតុផលជាច្រើនធ្វើឱ្យគេ មានសុទិដ្ឋិនិយមថា វាពិតជាអាចឆ្លងផុតពីវិបត្តិនេះ គឺដូចជាការធ្លាប់ជំនះបានលើបញ្ហាប្រឈមជាច្រើនហើយ តាំងពីពេលចូលដល់សតវត្សរ៍ទី២១ រហូតមក ។ ក្នុងនេះគេចាំបាច់ត្រូវដាក់អនុវត្តគោលនយោបាយមួយចំនួន សំរាប់ដោះស្រាយភាពងាយរងគ្រោះ ដែលបង្កឡើងដោយវិបត្តិ ។ ប៉ុន្តែដើម្បីឱ្យដំណោះស្រាយមានចីរភាពល្អ គេត្រូវលុបបំបាត់ចំណុចខ្វះខាតខាងរចនាសម្ព័ន្ធ ដែលរារាំងដល់ការរីកលូតលាស់វិស័យទេសចរណ៍ ។

គេមាន វិធានការសំរាប់ដោះស្រាយមួយចំនួនដែរ (ប្រអប់ ១) ។ គេត្រូវសង្កត់ធ្ងន់ជាពិសេស លើការចាប់ផ្តើមយុទ្ធនាការផ្សព្វផ្សាយទីផ្សារដ៏ទាក់ទាញមួយ ដោយត្រូវអនុម័តប្រើប្រធានបទដ៏គួរឱ្យចាប់ចិត្ត ដូចជា "កម្ពុជា-រាជាណាចក្រអច្ឆរិយ" ដែលប្រកួតប្រជែងបានជាមួយយុទ្ធនាការផ្សព្វផ្សាយនាពេលបច្ចុប្បន្នរបស់បណ្តាប្រទេសក្នុងតំបន់ ដូចជា "ថៃ ទេសចរណ៍នៃស្នាមញញឹមជាថ្មី" "វៀតណាមគួរឱ្យស្ញប់ស្ញែង" និង "ឡាវដ៏សាមញ្ញ" ។ កម្ពុជាអាចធ្វើយុទ្ធនាការផ្សព្វផ្សាយតូចៗតាមរយៈ ប៉ុស្តិ៍ CNN Discovery Channel និង នៅតាមប្រទេសគោលដៅមួយចំនួន ។ ផលប្រយោជន៍អាចទទួលបាន ប្រហែលជួយជំរុញរដ្ឋាភិបាលឱ្យផ្តោតការយកចិត្តទុកដាក់ភ្លាមៗទៅលើសំណើផ្សព្វផ្សាយទីផ្សារនេះ ។ នៅក្នុងកាលៈទេសៈពិសេសនាពេលសព្វថ្ងៃ វិស័យទេសចរណ៍គួរមានប្រើវិធីសាស្ត្រជំរុញការលក់កញ្ចប់ដំណើរកំសាន្ត ។ ការសំរួលបទបញ្ញត្តិផ្តល់ទិដ្ឋាការ និងការបង្កើនល្បឿនការងារត្រួតពិនិត្យ-ផ្តល់ទិដ្ឋាការ អាចបង្កើនចំណូលទេសចរណ៍បានពី ១0% ទៅ ២0% ។ យុទ្ធសាស្ត្ររយៈពេលវែងដទៃទៀត រួមមានការបង្កើតក្រុមហ៊ុនអាកាសចរណ៍ជាតិ និង ក្រុមប្រឹក្សាទេសចរណ៍ជាតិកម្ពុជា ។ អវត្តមាននៃក្រុមហ៊ុនអាកាសចរណ៍ជាតិ គឺជាឧបសគ្គធំបំផុតដល់ការរៀបចំប្រទេសកម្ពុជាឱ្យក្លាយជាគោលដៅទេសចរណ៍ ដ៏សំខាន់ក្នុងពិភពលោក ។ កង្វះការត្រួតពិនិត្យក្នុងវិស័យទេសចរណ៍ គឺជាឧបសគ្គចំបងមួយទៀតដែលត្រូវដោះស្រាយ ។ ឥឡូវនេះដល់ពេលវេលាណាស់ហើយ ដែលត្រូវបង្កើតក្រុមប្រឹក្សាទេសចរណ៍ជាតិកម្ពុជា (ប្រអប់ ២) ។

ភាគីទាំងអស់ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យទេសចរណ៍ គួររួបរួមគ្នាឡើង ។ ចូរយើងខំកសាងប្រទេសកម្ពុជា ទាំងអស់គ្នា!

### ប្រអប់ ១: យុទ្ធសាស្ត្រព្រោះព្រំវិស័យទេសចរណ៍ ឡើងវិញ

ជំរើស ១: សម្រួលបទបញ្ញត្តិផ្តល់ទិដ្ឋាការ និង បង្កើនល្បឿនដំណើរការធ្វើទិដ្ឋាការ តាមរយៈការបំពេញសំនុំបែបបទតាមអ៊ិនធឺណេត ការផ្តល់ទិដ្ឋាការឱ្យនៅពេលមកដល់ និងឈប់ប្រមូល ឬបញ្ចុះថ្លៃទិដ្ឋាការ ក្នុងអំឡុងពេលមានវិបត្តិសេដ្ឋកិច្ចសាកលនេះ ។

ជំរើស ២: បង្កើតកញ្ចប់ដំណើរកំសាន្តពិសេសៗ ។

ជំរើស ៣: ស្វែងរកទីផ្សារថ្មីៗនៅអាស៊ី និងជំរុញបន្ថែមការធ្វើដំណើរក្នុងស្រុក ។

ជំរើស ៤: ពង្រឹងទំនាក់ទំនងរឹងមាំ និងកសាងផែនការ ផ្ទៃក្នុងតំបន់ (កម្ពុជា-ឡាវ-វៀតណាម + ថៃ) សំរាប់ការផ្សព្វផ្សាយ និងធ្វើម៉ាឃីធីង ។

ជំរើស ៥: គិតគូរបង្កើត ក្រុមហ៊ុនអាកាសចរជាតិ ឡើងវិញ ។

ជំរើស ៦: ពង្រឹងការធ្វើម៉ាឃីធីងតាមយុទ្ធវិធីផ្សេងៗ ដូចជា យុទ្ធនាការពិសេសៗ ជាដើម

ជំរើស ៧: វិនិយោគបន្ថែមទៅលើផលិតផល និងសេវាទេសចរណ៍អាចប្រកួតប្រជែងបាន ដូចជា សេវាស្ប៉ា និងសេវាជម្រះអារម្មណ៍ ជាដើម ។

ជំរើស ៨: បង្កើតក្រុមប្រឹក្សាទេសចរណ៍ជាតិកម្ពុជា ។

**ប្រអប់ ២: ក្រុមប្រឹក្សាទេសចរណ៍ជាតិកម្ពុជា ទំនួលខុសត្រូវ និងតួនាទីដែលបានស្នើឡើង**

- បង្កើតយុទ្ធសាស្ត្រទេសចរណ៍ជាតិសំរាប់ឆ្នាំ២០០៩ និងតទៅមុខទៀត
- បង្កើតគោលនយោបាយ ច្បាប់ ក្រឹត្យ វិធាន និងបទបញ្ជាផ្សេងៗ ស្តីពីការធ្វើដំណើរ និងទេសចរណ៍
- ធ្វើសកម្មភាពខាងទីផ្សារផ្សេងៗ ដើម្បីជំរុញទេសចរណ៍
- ជំរុញការអភិវឌ្ឍធនធានមនុស្សសំរាប់ទេសចរណ៍ និងពង្រឹងការកសាងសមត្ថភាព
- ប្រើប្រាស់ និងត្រួតពិនិត្យលើមូលនិធិផ្សព្វផ្សាយ និងអភិវឌ្ឍន៍ទេសចរណ៍
- សម្របសម្រួល និងសហការណ៍ជាមួយភ្នាក់ងារពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ដើម្បីអភិវឌ្ឍ និងកែលំអភាពទាក់ទាញភ្ញៀវទេសចរ លើកកំពស់ប្រពៃណី និងវប្បធម៌កម្ពុជា ក៏ដូចជា អភិរក្ស និងការពារបេតិកភ័ណ្ឌ និងការប្រើប្រាស់ផលិតផលក្នុងស្រុក
- ណែនាំ ត្រួតពិនិត្យ និងសម្របសម្រួលជាមួយ សមាគមទីភ្នាក់ងារទេសចរណ៍កម្ពុជា សមាគមសណ្ឋាគារកម្ពុជា និងសមាគមភោជនីយដ្ឋានកម្ពុជា ។
- សហការណ៍ជាមួយអង្គការទេសចរណ៍ថ្នាក់អនុតំបន់ និងអន្តរជាតិ ក៏ដូចជា បណ្តាអង្គការអន្តរជាតិដែលពាក់ព័ន្ធ នឹងទេសចរណ៍
- ចាត់ចែង តាមដាន និងត្រួតពិនិត្យ ការអនុវត្តផែនការទេសចរណ៍
- ជំរុញទេសចរណ៍ និងអាជីវកម្មខាងទេសចរណ៍ ដើម្បីលើកកំពស់ជីវភាពរបស់ប្រជាជន និងជំរុញការដាក់បញ្ចូល ប្រើប្រាស់ផលិតផលក្នុងមូលដ្ឋាន
- លើកកំពស់សិល្បៈ វប្បធម៌ និងប្រពៃណីកម្ពុជា និង ការពារបូជនីយដ្ឋានប្រវត្តិសាស្ត្រ និងបុរាណវត្ថុ ដើម្បីទាក់ទាញភ្ញៀវទេសចរបរទេសឱ្យចូលមកទស្សនា
- ផ្តល់ការងារថ្មីៗ និងបង្កើតឱកាសរកប្រាក់ចំណូលប្រសើរជាងមុនសំរាប់ជនជាតិភាគតិច
- ពង្រីកចំណងមិត្តភាព និងសហប្រតិបត្តិការល្អជាមួយគ្រប់ប្រទេស ស្របតាមគោលនយោបាយរបស់រដ្ឋាភិបាល ។

**តើអ្នកដឹងទេថា**

... នៅឆ្នាំមុន មានការព្យាយាមម្តងទៀត ដើម្បីបង្កើតក្រុមហ៊ុនអាកាសចរជាតិថ្មីមួយ? នៅខែមេសា ២០០៨ រដ្ឋាភិបាលកម្ពុជា បានចុះកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុន Rajawali ឥណ្ឌូនេស៊ី លើការដេញថ្លៃការចាប់ដំណើរការក្រុមហ៊ុនអាកាសចរជាតិឡើងវិញ ។ តាមកិច្ចព្រមព្រៀង កម្ពុជានឹងទទួលបានភាគហ៊ុន ៥១% ក្នុងគំរោងថ្មី ។ ប៉ុន្តែគួរឱ្យស្តាយ ដោយសារមូលហេតុផ្សេងៗ ដូចជា វិបត្តិកាន់តែធ្ងន់ធ្ងរ និងការលំបាកក្នុងកិច្ចចរចារវាងគូភាគី ផែនការនេះក៏ត្រូវផ្អាកទៅវិញ ។ អាកាសចរភូមិន្ទកម្ពុជា គឺជាក្រុមហ៊ុនអាកាសចរណ៍ជាតិដំបូង របស់កម្ពុជា ដែលបានដំណើរការនៅពាក់កណ្តាលទសវត្សរ៏១៩៩០ ប៉ុន្តែត្រូវដួលរលំទៅវិញ ។

*ប្រភព : សារព័ត៌មាន Reuters (2008) និង សារពតិមានភ្នំពេញប៉ុស្តិ៍ (២០០៨)*